**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

DBD ENGINEERING

លេខ: ៣៣៧/២៣ ឧបឧ

# សេចក្តីជូនដំណឹង

## ស្តីពី

## វិសោធនកម្មលក្ខន្តិកៈរបស់ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

**ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** ("ក្រុមហ៊ុន ឌី ប៊ី ឌី") មានកិត្តិយស សូមជម្រាបជូនដំណឹងដល់សាធារណៈជន និងភាគហ៊ុនិកទាំងអស់មេត្តាជ្រាបថា ក្រសួងពាណិជ្ជកម្ម បានទទួលស្គាល់ការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់ក្រុមហ៊ុន ឌី ប៊ី ឌី ដូចខាងក្រោមៈ

**១- ការបង្កើនដើមទុនចុះបញ្ជីរបស់ក្រុមហ៊ុន**

| មុនពេលផ្លាស់ប្តូរ | បន្ទាប់ពីផ្លាស់ប្តូរ |
|---|---|
| ដើមទុនចុះបញ្ជីចាស់ចំនួន ១២.០០០.០០០.០០០ រៀល បែងចែកជា ១២.០០០.០០០ ភាគហ៊ុន ដែលក្នុងមួយភាគហ៊ុនមានតម្លៃចារឹកស្មើនឹង ១.០០០ រៀល | ដើមទុនចុះបញ្ជីថ្មីចំនួន ១៨.៤៦១.៥៣៨.០០០ រៀល បែងចែកជា១៨.៤៦១.៥៣៨ ភាគហ៊ុន ដែលក្នុងមួយភាគហ៊ុនមានតម្លៃចារឹកស្មើនឹង ១.០០០ រៀល |

**២- ការតែងតាំងអភិបាលមិនប្រតិបត្តិមួយរូបតំណាងពីក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប**

លោក **វ៉ាមីបាស៊ា អាសាត សារាហ្វ** ត្រូវបានតែងតាំងជាអភិបាលថ្មី (តំណាងក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប) របស់ក្រុមហ៊ុន ឌី ប៊ី ឌី ដែលប្រសិទ្ធភាពនៃថ្ងៃលោក **វ៉ាមីបាស៊ា អាសាត សារាហ្វ** ចូលកាន់តំណែងគឺនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២។ ដូច្នេះសមាសភាពក្រុមប្រឹក្សាភិបាលថ្មីរបស់ក្រុមហ៊ុន ឌី ប៊ី ឌី មានដូចខាងក្រោមៈ

| ល.រ | សមាសភាពក្រុមប្រឹក្សាភិបាល | មុខតំណែង |
|---|---|---|
| ១ | លោក នាង វិធី | ប្រធានក្រុមប្រឹក្សាភិបាល |
| ២ | លោកស្រី លឹម មុយលី | អភិបាលប្រតិបត្តិ |
| ៣ | លោក ហ៊ុយ វ៉ាថារ៉ូ | អភិបាលឯករាជ្យ |
| ៤ | លោក ថៃ វ៉ាន់ថា | អភិបាលមិនប្រតិបត្តិ |
| ៥ | លោក វ៉ាមីបាស៊ា អាសាត សារាហ្វ | អភិបាលមិនប្រតិបត្តិ |

## ៣- ការផ្លាស់ប្តូរអាសយដ្ឋានទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន

ដើម្បីងាយស្រួលក្នុងការទំនាក់ទំនងជាមួយអតិថិជន និងស្របតាមសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី បានសម្រេចលើការផ្លាស់ប្តូរអាសយដ្ឋានទីស្នាក់ការចុះបញ្ជីក្រុមហ៊ុនពីអាសយដ្ឋានចាស់ទៅអាសយដ្ឋានថ្មីដូចខាងក្រោម៖

| ទីស្នាក់ការចុះបញ្ជីចាស់ | ទីស្នាក់ការចុះបញ្ជីថ្មី |
| --- | --- |
| ផ្ទះលេខ៦៨ ផ្លូវលេខ៥៩៨ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ | ក្បាលដីលេខ ១២៩៨ ផ្លូវបេតុង ភូមិស្វាយចេក សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជន និងភាគហ៊ុនិកទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣

**ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក
DBD ENGINEERING
Plc.
KINGDOM OF CAMBODIA